00225304

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C26/I/29

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌ លេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៤)

ចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន័យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

កាលបរិច្ឆេទ: ២ តុលា ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 02 / OCT / 2008
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ty

---

សាធារណៈ:

**សេចក្តីបង្គាប់ស្តីពីការបន្តកិច្ចដំណើរការនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន**

---

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 02 / Oct / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT
ពេជ្រ សម្បត្តិ
Alex BATES

**ជនត្រូវចោទ**

ខៀវ សំផន

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន
ឡោ ជុនធី
នី ចាន់ឌី
គង់ ពិសី
Silke STUZINSKY
យុង ផានិត
គឹម ម៉េងឃី
Martine JACQUIN

**សហមេធាវីការពារក្តី**

សរ សុវ៉ាន
Jacques VERGES

១. **អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (“**អវតក**”) កត់សម្គាល់ឃើញមាន “បណ្តឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧” ដែលសហមេធាវីការពារក្តីរបស់ជនត្រូវចោទបានប្តឹងឧទ្ធរណ៍ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ (“បណ្តឹងឧទ្ធរណ៍”)។

២. នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ សវនាការលើបណ្តឹងឧទ្ធរណ៍បានចាប់ផ្តើម។ ប៉ុន្តែ ផ្អែកតាមពាក្យសុំរបស់ជនត្រូវចោទ អង្គបុរេជំនុំជម្រះបានលើកពេលសវនាការ “ទៅថ្ងៃក្រោយដោយធ្វើការជូនដំណឹងតាមក្រោយ”។[1]

៣. ជនត្រូវចោទ ឬមេធាវីការពារក្តីរបស់ខ្លួន (មេធាវី) មិនបានផ្តល់ដំណឹង ជូនអង្គបុរេជំនុំជម្រះ ក្រោយពីការលើកពេលសវនាការ។ ដូច្នេះ នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានចេញសេចក្តីបង្គាប់មួយដល់មេធាវីឱ្យធ្វើការបង្ហាញពីជំហររបស់ខ្លួនចំពោះបណ្តឹងឧទ្ធរណ៍នេះ។

៤. នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានដាក់ “សេចក្តីជូនដំណឹងអំពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន” (“សេចក្តីជូនដំណឹង”)។

៥. នៅក្នុងសេចក្តីជូនដំណឹងនេះ សហមេធាវីការពារក្តីបានជម្រាបអង្គបុរេជំនុំជម្រះថា ខ្លួន “ទាមទារឱ្យមានការបកប្រែទាំងស្រុងនូវឯកសារសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន។ ដរាបណាការបកប្រែមិនត្រូវបានគេធ្វើទេនោះ សហមេធាវីការពារក្តីនឹងពុំអាចធ្វើកិច្ចសហប្រតិបត្តិការជាមួយតុលាការ បានឡើយ។ ដូច្នេះ សហមេធាវីការពារក្តី និងជនត្រូវចោទ សូមស្នើដោយទទូចទៅអង្គបុរេជំនុំជម្រះមេត្តាពិនិត្យលទ្ធភាពឱ្យមានការបកប្រែជាអាទិភាព។ បើមិនដូច្នេះទេ ការឃុំខ្លួនលោក ខៀវ សំផន នឹងមិនមានមូលដ្ឋានច្បាប់ទេ ដោយហេតុថារហូតមកទល់នឹងពេលនេះ មេធាវីបរទេសរបស់គាត់ពុំដឹងថាតើកូនក្តីរបស់គាត់ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ដោយបទចោទប្រកាន់ណាមួយឡើយ។”[2]

៦. អង្គបុរេជំនុំជម្រះកត់សម្គាល់ឃើញថា នៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ សហមេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះ “ឱ្យសម្រេច និងកាត់ក្តីថា លោក ខៀវ សំផន ពុំមានជាប់ពិរុទ្ធភាពអ្វីទៀតឡើយ ពីព្រោះ

---

[1] សេចក្តីសម្រេចលើពាក្យសុំពន្យារពេលសវនាការបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ C26/I/25 ទំព័រទី ៤។

[2] សេចក្តីជូនដំណឹងអំពីគោលជំហររបស់ក្រុមការពារក្តីទៅអង្គបុរេជំនុំជម្រះ ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ C26/I/8 វាក្យខណ្ឌទី៩ និងវាក្យខណ្ឌទី១០។

លោក ខៀវ សំផន ត្រូវបានទទួលស្គាល់ថា គាត់គ្មានអំណាចជាក់ស្តែងសម្រាប់បង្គាប់បញ្ជាអ្នកណា ឬអង្គភាពចាត់តាំងលំដាប់ថ្នាក់ណាមួយបានឡើយ ហើយគាត់គ្រាន់តែជាប្រមុខរដ្ឋមានតែឈ្មោះប៉ុណ្ណោះ"[3]។ សហមេធាវីការពារក្តីស្នើសុំអង្គបុរេជំនុំជម្រះឱ្យបដិសេធដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយមូលហេតុគ្មានពិរុទ្ធភាពលើរូបលោក ខៀវ សំផន។"[4]

៧. សារណាបណ្តឹងឧទ្ធរណ៍មិនបានលើកបញ្ហាបកប្រែ ឬពុំមានលទ្ធភាពក្នុងការតវ៉ា "បទចោទដែលត្រូវបានយកមកធ្វើជាមូលដ្ឋាននៃការឃុំខ្លួនជនត្រូវចោទបណ្តោះអាសន្នឡើយ"។

៨. វិធាន ៧៥(៤) នៃវិធានផ្ទៃក្នុងចែងថា:

> ការដាក់សារណាបណ្តឹងឧទ្ធរណ៍ ត្រូវមានបញ្ជាក់អំពីអំណះអំណាងខាងអង្គហេតុ និង អង្គច្បាប់ ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ ដោយមានភ្ជាប់មកជាមួយនូវឯកសារសំអាងទាំងនោះ។ ម្ចាស់បណ្តឹងឧទ្ធរណ៍មិនអាចលើកក្នុងពេលសវនាការ បញ្ហាអង្គហេតុឬអង្គច្បាប់ដែលមិនមានចែងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍ឡើយ ។

៩. អង្គបុរេជំនុំជម្រះយល់ឃើញថា វិធាន ៧៥(៤) រារាំងមេធាវី ចំពោះការលើកឡើងអង្គហេតុ និងអង្គច្បាប់បន្ថែម នៅក្នុងដំណាក់កាលនេះ ដែលអង្គហេតុ និងអង្គច្បាប់ទាំងនេះ មិនបានលើកឡើងនៅក្នុងសារណាបណ្តឹងឧទ្ធរណ៍។

១០. នៅពេលធ្វើការពិចារណាព័ត៌មាន ដែលបានលើកឡើងនៅក្នុងសេចក្តីជូនដំណឹង អង្គបុរេជំនុំជម្រះយល់ឃើញថា គ្មានហេតុផលណាមួយ ដែលត្រូវពន្យារពេលបន្តទៀតក្នុងការចេញសាលដីកាលើបណ្តឹងឧទ្ធរណ៍នេះឡើយ។

១១. សេចក្តីប្រកាសរបស់សហមេធាវីការពារក្តីជនត្រូវចោទ ចំពោះសេចក្តីសន្និដ្ឋានផ្ទាល់មាត់លើបណ្តឹងឧទ្ធរណ៍ ត្រូវបានយល់ឃើញថា ជាការបដិសេធបន្តចូលរួមនៅក្នុងសវនាការដេញដោល។

១២. វិធាន ៧៧(៣)(ខ) នៃវិធានផ្ទៃក្នុងចែងថា:

> បន្ទាប់ពីបានពិចារណាលើការយល់ឃើញរបស់ភាគី អង្គបុរេជំនុំជម្រះអាចសម្រេចលើបណ្តឹងឧទ្ធរណ៍ ឬ ពាក្យសុំ ដោយផ្អែកតែលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់ភាគីតែប៉ុណ្ណោះ។

---

[3] សារណាបណ្តឹងឧទ្ធរណ៍ចំពោះដីកាបង្គាប់ការឃុំខ្លួនបណ្តោះអាសន្ននៃថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧, ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ C26/I/3 ("សារណាបណ្តឹងឧទ្ធរណ៍") ទំព័រទី១២។

[4] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រទី ១២។



PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. C.E.T.C.

00225307



១៣. ដោយធ្វើការពិចារណាកាលៈទេសៈដែលថា សេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់ភាគីដទៃទៀត អាចធ្វើឡើងបន្ទាប់ពីសេចក្តីសន្និដ្ឋានផ្ទាល់មាត់របស់សហមេធាវីការពារក្តី និងការធ្វើសេចក្តីសន្និដ្ឋានផ្ទាល់មាត់ទាំងនេះមិនអាចធ្វើទៅបាន ដោយសារឥរិយាបទរបស់មេធាវី អង្គបុរេជំនុំជម្រះយល់ឃើញថា បណ្តឹងឧទ្ធរណ៍នេះ ត្រូវយកមកសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែម្តង ដោយមិនចាំបាច់ស្នើសុំការយល់ឃើញរបស់ភាគីឡើយ។

១៤. អនុលោមតាមមាត្រា ៨(៤) នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អ.វ.ត.ក មេធាវីត្រូវបានអនុញ្ញាតឱ្យដាក់សារណាតប។

## ហេតុដូច្នេះអង្គបុរេជំនុំជម្រះ÷

(១) **សម្រេចថា** បណ្តឹងឧទ្ធរណ៍នេះនឹងយកមកសម្រេច ដោយផ្អែកលើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ។

(២) **បង្គាប់ឱ្យ** មេធាវីដាក់សារណាតប ប្រសិនបើមាន ក្នុងរយៈពេល **ប្រាំពីរ (៧) ថ្ងៃ** គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ទាំងនេះ។ ៧

ភ្នំពេញ ថ្ងៃទី២ ខែតុលា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE ECCC CETC

**ប្រាក់ គឹមសាន**